**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ: ៤៧០ កប/ប្រ.ក

# ប្រកាស

## ស្តីពី

## ការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តព្រះវិហារ

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យនស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការ រៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៥២ អន.ក្រ.បក ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រង គ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- តាមសំណើ លេខ ១៣៣/០៩ មកបវ/ពហ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០០៩ របស់លោកប្រធាន មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តព្រះវិហារ

## សម្រេច

**ប្រការ ១ :** បង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមួយ ដែលមានឈ្មោះថា " មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តព្រះវិហារ " (មបវ.ខពហ) ។ មជ្ឈមណ្ឌលនេះ ទីតាំងស្ថិតនៅក្នុងខេត្តព្រះវិហារ ហើយស្ថិតនៅក្រោមឱវាទក្រសួងការងារ និងបណ្តុះ បណ្តាលវិជ្ជាជីវៈ និងគ្រប់គ្រងផ្ទាល់ដោយមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តព្រះវិហារ។

ប្រការ ២ ៖ មជ្ឈមណ្ឌលមានភារកិច្ច ៖

- ធ្វើការប៉ាន់ប្រមាណ និងលើកគម្រោងតម្រូវការបណ្តុះបណ្តាល ។
- ធ្វើការបណ្តុះបណ្តាលវិជ្ជាជីវៈឱ្យឆ្លើយតបទៅនឹងតម្រូវការរបស់ខេត្ត និងតំបន់ ។
- សហការជាមួយអង្គការនានាដើម្បីពង្រឹង និងពង្រីកការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ។
- ធ្វើរបាយការណ៍ពីសកម្មភាពបណ្តុះបណ្តាលជូនមកក្រសួង តាមរយៈនាយកដ្ឋានគ្រប់គ្រងកិច្ចការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ។
- អនុវត្តតាមគោលការណ៍ណែនាំ សេចក្តីប្រកាស និងសារាចរណែនាំរបស់អភិបាលខេត្ត និងក្រសួង ។

ប្រការ ៣ ៖ មជ្ឈមណ្ឌលនេះមានឋានៈស្មើនឹងការិយាល័យ នៃមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី និងខេត្ត ។

ប្រការ ៤ ៖ នាយកមជ្ឈមណ្ឌលមានបុព្វសិទ្ធិស្មើនឹងប្រធានការិយាល័យ នៃមន្ទីរការងារ និងបណ្តុះបណ្តាល និងវិជ្ជាជីវៈ រាជធានី និងខេត្ត ហើយមាននាយករងមួយចំនួនជាជំនួយការតាមការចាំបាច់ ។

ប្រការ ៥ ៖ ចំពោះមុខមជ្ឈមណ្ឌលមានផ្នែកការងារជាប្រចាំដូចតទៅ ៖

១-ផ្នែករដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ

២-ផ្នែកសិក្សាអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

៣-ផ្នែកផែនការ និងទំនាក់ទំនងទីផ្សារ

ទៅអនាគតមជ្ឈមណ្ឌលនឹងស្នើសុំផ្នែកដទៃទៀតតាមតម្រូវការជាក់ស្តែង ។

ប្រការ ៦ ៖ នាយកខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយក នៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នាយកដ្ឋានគ្រប់គ្រងកិច្ចការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តព្រះវិហារ មានភារកិច្ចរៀងៗខ្លួនប្រតិបត្តិតាមប្រកាសនេះ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ ២០០៩

រដ្ឋមន្ត្រី

វង សូត

**ចំលងជូន**

-ខុទ្ទកាល័យលោកជំទាវឧបនាយករដ្ឋមន្ត្រីប្រចាំការ

-ទីស្តីការគណៈរដ្ឋមន្ត្រី

-សាលាខេត្តព្រះវិហារ

-ដូចប្រការ ៦ " ដើម្បីអនុវត្ត "

-ឯកសារ-កាលប្បវត្តិ